ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣
ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២
សំណុំរឿងស៊ើបសួរលេខ ១៤
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២
សំណុំរឿងជំនុំជម្រះលេខ ២០៦
ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌលេខ**៥៤០**"ជ"
ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០២២

សាលក្រមព្រហ្មទណ្ឌ

ក្នុងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទបើកសវនាការ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក។
ដែលមានសមាសភាពដូចតទៅ ៖

ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពត

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពត

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពត

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **នួន** ភេទប្រុស កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៥ ជនជាតិខ្មែរ មុខរបរអាជីវករ ទីកន្លែងកំណើត[redacted]ខេត្តតាកែវ និងទីលំនៅ(មុនពេលឃុំខ្លួន)នៅផ្ទះលេខ ៧៥A ភូមិអង្គកែវ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]ប៊ុនណូ (ស) ម្តាយឈ្មោះ [redacted]ម៉ាន (រ) ពោះម៉ាយ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុនគ្មាន (ក្រៅឃុំ)

ជាប់ចោទពីបទ **ឆបោក** និងបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិព្រៃពាយ និងភូមិដុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត កាលពីអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្ន បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាម **មាត្រា៣៧៧ មាត្រា៣៧៨ មាត្រា៣៩១ និងមាត្រា៣៩២** នៃក្រមព្រហ្មទណ្ឌ ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នួន ។
មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នួន។
មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នួន ។
មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នួន។
មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] នួន ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុល ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមន្ត្រីរាជការ មានទីលំបច្ចុប្បន្ននៅផ្ទះលេខ G៣៦B ផ្លូវបេតុង ក្រុម១៣ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

មានលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុល ។

ត្រូវបានបញ្ជូនមកជំនុំជម្រះតាម ដីកាដំណោះស្រាយលេខ៧៩៨"ឈ"ព្រទ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត។

អង្គហេតុដែលថ្កើងមកតុលាការមានដូចតទៅ:

កាលពីអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០២១ រហូតមកដល់បច្ចុប្បន្នមានករណី **ឆបោក និងរំលោភលើទំនុកចិត្ត** មួយបានកើតឡើង ស្ថិតនៅចំណុចភូមិព្រៃពាយ និងភូមិដុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] នួន ភេទប្រុស កើតនៅឆ្នាំ១៩៧៥ ដោយជនជាប់ចោទបានអះអាងថាខ្លួនជាម្ចាស់ដីចំហំ ១០៥០ហិកតា ហើយបានធ្វើសកម្មភាពលក់ដីមកឲ្យជនរងគ្រោះឈ្មោះ [redacted] ប៊ុល ភេទប្រុស អាយុ ៣៨ឆ្នាំ ដោយក្នុងមួយហិកតាតម្លៃ៥៥00ដុល្លារអាមេរិក មានតម្លៃសរុបប្រហែល0៥(ប្រាំ)លានដុល្លារអាមេរិក។ ក្រោយពីឈ្មោះ [redacted] ប៊ុល បានប្រគល់ប្រាក់ប្រហែល៨២ម៉ឺនដុល្លារអាមរិក នៅក្នុងអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០២១ ទៅឲ្យឈ្មោះ [redacted] នួន រួចមកឃើញថាដីមួយចំនួនមិនមែនជាដីរបស់ឈ្មោះ [redacted] នួន ទាំងអស់នោះឡើយ គឺជាដីរបស់ប្រជាពលរដ្ឋចំហំប្រហែល៨៣៦ហិកតា ។ ក្រោយពីទទួលបានលុយមួយចំនួនពីឈ្មោះ [redacted] ប៊ុល រួចមកឈ្មោះ [redacted] នួន មិនបានប្រគល់លុយគ្រប់ចំនួនទៅឲ្យប្រជាពលរដ្ឋជាម្ចាស់ដីពិត លើដីចំហំ៨៣៦ ហិកតានោះទេ ដែលជាហេតុធ្វើឲ្យប្រជាពលរដ្ឋជាម្ចាស់ដី បានធ្វើការតវ៉ាមិនឲ្យឈ្មោះ [redacted] ប៊ុល ចូលមកកាន់កាប់ដីតាមចំហំដែលទិញពីឈ្មោះ [redacted] នួន នោះបានឡើយ។ ក្រោយមកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹង និងឈានដល់ឃាត់ខ្លួនឈ្មោ [redacted] នួន បញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពត នៅថ្ងៃទី១៣ ខែមករា ឆ្នាំ ២០២២ ដើម្បីចាត់ការទៅតាមច្បាប់ ។

បានជាការត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ខែ ឆ្នាំ ព.ស ២៥៦៦
នាំ ថ្ងៃទី ខែ ឆ្នាំ

សារពេលសវនាការ

-ក្រោយពីបាន សួរ និងស្តាប់ចម្លើយជនជាប់ចោទឈ្មោះ ប៉ែន នួន ។

-ក្រោយពីបានស្តាប់ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សុិន បុល និងឈ្មោះ ញ៉ែម រ៉

-ក្រោយពីបានស្តាប់ អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ពិសិដ្ឋ ឈ្មោះ [redacted] ប៊ុនធឿន ឈ្មោះ [redacted] ចាន់ ឈ្មោះ [redacted] ផាត ឈ្មោះ [redacted] ឈឿន ឈ្មោះ [redacted] ស៊ុលាង ឈ្មោះ [redacted] ថុង និង [redacted] វីរៈ ។

- ក្រោយពីបានស្តាប់ក្រឡាបញ្ជីអានរបាយការណ៍ និងឯកសារកំណត់ហេតុ ។
- ក្រោយពីបានស្តាប់តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការ
- ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិ ឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន
- ក្រោយពីបានស្តាប់សំដីចុងក្រោយជនជាប់ចោទឈ្មោះ [redacted] នួន ។

សំអាងហេតុ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់រួចហើយ តុលាការយល់ឃើញថា ៖

១-ជនជាប់ចោទឈ្មោះ [redacted] នួន ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះ ពីបទ **ឆបោក** និងបទ **រំលោភលើទំនុកចិត្ត** តាមរយៈដីកាដំណោះស្រាយ ។ ចំពោះរឿងនេះ គឺជាបទមជ្ឈិម ដែលតុលាការអាចជំនុំជម្រះ និងសម្រេចដោយចៅក្រមទោល ដោយផ្អែកតាម **មាត្រា ២៩១ និងមាត្រា ៣៥៨** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] នួន បានឆ្លើយនាពេលសវនាការថា ខ្លួនមិនទទួលស្គាល់ការចោទប្រកាន់របស់តំណាងអយ្យការនោះទេ។ កន្លងមកខ្លួនពុំដែលស្គាល់ដើមបណ្តឹងទេ គឺលោកមេឃុំឈ្មោះ [redacted]ធ៌ ជាអ្នកណែនាំឱ្យស្គាល់។ ក្រោយមកដើមបណ្តឹងឈ្មោះ [redacted] បុល និងឈ្មោះ [redacted] ឡុង បានមកទិញដីពីខ្លួនចំនួនជាង ១០០០ហិកតា ដោយឱ្យកន្លែងខ្លះមួយហិកតា តម្លៃ៥០០០ដុល្លារ និងកន្លែងខ្លះ តម្លៃ ២៥០០ដុល្លារ ដោយបានធ្វើកិច្ចសន្យាកក់ប្រាក់ត្រឹមត្រូវទៀតផង ។ មុនដើមបណ្តឹងទិញដីពីខ្លួន ដីនោះខ្លួន និងឈ្មោះ [redacted] ប៊ុនធឿន បានប្រមូលទិញពីប្រជាពលរដ្ឋបានខ្លះ និងកក់ប្រាក់ខ្លះ បានផ្ទៃដីសរុបចំនួន១៥០០០ហិកតា ដោយទិញពីប្រជាពលរដ្ឋចំនួន២២៦គ្រួសារ ។ មុនពេលដើមបណ្តឹងទិញដីពីខ្លួនគាត់ក៏បានដឹងដែរថាដីនេះពុំមានប្តង់ទេ ហើយខ្លួនគ្រាន់តែជាអ្នកតំណាងឱ្យប្រជាពលរដ្ឋប៉ុណ្ណោះ។ ពេលធ្វើការទិញលក់ជាមួយឈ្មោះ [redacted] បុល ខ្លួនធ្វើកិច្ចសន្យាត្រឹមតែភាគីនិងមានមេធាវីប៉ុណ្ណោះ ពុំមានអាជ្ញាធរទទួលស្គាល់ទេ។ ក្រោយពីទិញដីពីខ្លួនរួចមក ដើមបណ្តឹងពុំបានធ្វើការឈូសឆាយនោះទេ ខ្លួន និងប្រជាពលរដ្ឋបានស្នើសុំឱ្យគាត់ធ្វើការឈូសឆាយ ព្រោះខ្លាចមានជនខិលខូចចូលមកកាន់កាប់តែដើមបណ្តឹងពុំព្រមដដែល។ ខ្លួនគ្រាន់តែជាអ្នកចូលរួមកក់ដីតំណាងឱ្យប្រជាពលរដ្ឋទេ ហើយភាគីអ្នកទិញស្នើសុំថាគាត់ចូលរួមប្រគល់ប្រាក់ទៅប្រជាពលរដ្ឋដែរ ពេលកក់ប្រាក់ប្រជាពលរដ្ឋខ្លួនសន្យាថានឹងឱ្យគ្រប់ចំនួន ២៤ខែ ប៉ុន្តែក្រោយមកខាងអ្នកទិញមិនបានទូរទាត់ប្រាក់មកឱ្យខ្លួន និងប្រជាពលរដ្ឋនោះទេ ដូច្នេះទើបផ្ទុះការតវ៉ា ពីប្រជាពលរដ្ឋដូចនេះ។ ចំពោះប្រាក់កក់មុននោះមានចំនួន៥០ម៉ឺនដុល្លារ នៅសល់អ្នកទិញនឹងបង់គ្រប់រយៈពេល២៤ខែ គឺ ១៩ម៉ឺនដុល្លារ ក្នុងមួយខែ ប៉ុន្តែដល់ពេលកំណត់ដើមបណ្តឹងមិនបានបង់ឱ្យប្រជាពលរដ្ឋនោះទេ ។ បច្ចុប្បន្នផ្ទៃដីចំនួន ១១៥ហិកតាហើយ ដែលដើមបណ្តឹងបានកាន់កាប់ ហើយលុយគាត់បានប្រគល់មកខ្លួនមានប្រហែលចំនួន ៨២ម៉ឺនដុល្លារហើយ។ ចម្លើយនេះគ្រាន់តែជាចម្លើយដោះសាររបស់ជនជាប់ចោទប៉ុណ្ណោះ ពុំមានសាក្សី ឬភស្តុតាងណាមកបញ្ជាក់ ដែលអាចឱ្យតុលាការជឿជាក់បាននោះឡើយ ។

ពន្ធដែលមានតឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី..១..ខែ..ធ.ន្ធ..ឆ្នាំ..ច..ស..ព.ស..ត..ន..ត..ស..ព.ស..ត..ន..ត..ស..ព.ស..ត..ន..ត

ដើម្បីកាយព្រំដីចំនួន ១០៥០ហិកតា នោះបាន ប៉ុន្តែពេលអ្នកទិញដាក់គ្រឿងចក្រចូលឈូសឆាយឈ្មោះ [redacted] នួន បានពន្យាពេលថាប្រជាពលរដ្ឋមិនទាន់ចេញអស់ ក្រោយមកឈ្មោះ [redacted] នួន នៅតែបន្តសុំឲ្យដើមបណ្តឹងទូរទាត់ប្រាក់មកជាបន្តបន្ទាប់មានចំនួនសរុប ៨៦៧៥០០ដុល្លារ តែពេលដើមបណ្តឹងចុះធ្វើការឈូសឆាយនៅតែប្រជាពលរដ្ឋមានការតវ៉ាដដែល ។ ក្រោយមកដើមបណ្តឹងក៏បានចុះសិក្សាមើលក៏ឃើញថា ផ្ទៃដីចំនួន១០៥០ហិកតា នោះ គឺមានដីជារបស់ឈ្មោះ [redacted] នួន តែចំនួនតិចតួចប៉ុណ្ណោះ ដីផ្សេងទៀត គឺជារបស់ប្រជាពលរដ្ឋ ។ ដូច្នេះចម្លើយនេះស៊ីសង្វាក់ជាមួយអង្គហេតុ និងលទ្ធផលស្រាវជ្រាវ របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿង អាចឲ្យតុលាការជឿជាក់បាន ។

៤-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា បន្ទាប់ពីសវនាការរួច តំណាងអយ្យការសុំរក្សាការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] នួន ដូចក្នុងដីកាសន្និដ្ឋានស្តាពរ ដដែល និងសុំឲ្យចៅក្រមជំនុំជម្រះពិនិត្យពិចារណាតាមភស្តុតាង និងសម្រេចផ្តន្ទាទោសជនល្មើសទៅតាមច្បាប់។ ចំណែកមេធាវីការពារសិទ្ធិជនជាប់ចោទបានសន្និដ្ឋានថា នៅក្នុងកិច្ចសន្យាលក់ទិញដីដើមបណ្តឹងបានស្នើសុំចូលរួមចែកលុយ ឲ្យប្រជាពលរដ្ឋដែរ ដូច្នេះដើមបណ្តឹងបានដឹងរួចទៅហើយថាដីនេះមួយចំនួនជារបស់ប្រជាពលរដ្ឋ ។ ហើយក្នុងកិច្ចសន្យាបញ្ជាក់ផងដែរថាដីនេះមានជាប់ពាក់ព័ន្ធគំរបព្រៃឈើ ហើយក៏ដឹងដែរថាកូនក្តីខ្លួនជាអ្នកតំណាង ពុំមែនកូនក្តីខ្លួនមានភាគព្វកិច្ចតែម្នាក់ឯងទេ។ ចំពោះលុយកក់បានមកចំនួន៥០ម៉ឺនដុល្លារ កូនក្តីខ្លួនបានទទួលតែចំនួន២២ម៉ឺនដុល្លារជាងទេ គឺដើម្បីយកទៅដោះស្រាយកក់ដីបន្តទៀត ហើយលុយសល់ផ្សេងទៀត គឺឈ្មោះ [redacted] បុល និងឈ្មោះ [redacted] ប៊ុនធឿន ជាអ្នកយកទៅចែកប្រជាពលរដ្ឋផ្ទាល់។ យោងតាមសវនាការមកនេះកូនក្តីខ្លួនមានចេតនាសុច្ចរិត ក្នុងការទិញលក់និងទទួលខុសត្រូវ តែដើមបណ្តឹងទេដែលមិនគោរពកិច្ចសន្យាបង់ប្រាក់ ដូច្នេះសូមសាលាដំរីបញ្ជាក់ដីលក់កូនក្តីខ្លួនផង។ ចំពោះសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ និងមេធាវី... ឲ្យតុលាការពិចារណា និងសម្រេចបាន ។

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី..១៧..ខែ..មករា..ឆ្នាំ..ព.ស២៥៦៧
ក្រុមប្រឹក្សាភិបាល

៥-យោងតាម **មាត្រា៣៧៧** នៃក្រមព្រហ្មទណ្ឌ ចែងថា "អំពើឆបោក គឺជាអំពើបន្តចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ ៖ ២-ការផ្តត់ផ្តង់សេវា"។ ហើយតាម **មាត្រា៣៧៨** នៃក្រមដដែល ចែងថា "អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦(ប្រាំមួយ)ខែ ទៅ ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន)រៀល"។ ជាមួយគ្នាដែរតាម **មាត្រា៣៩១** នៃក្រមដដែលចែងថា "អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយនាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់ ។" ម៉្យាងទៀតតាន មាត្រា៣៩២ នៃក្រមដដែលចែងថា "**អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦(ប្រាំមួយ)ខែ ទៅ ០៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ ៦.០០០.០០០(ប្រាំមួយលាន)រៀល**"។

៦-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នួន ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងក្នុងសំណុំរឿង ឃើញថា នាទីកន្លែងកើត ក្នុងអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ ២០២១ នោះ ជនជាប់ចោទឈ្មោះ [redacted] នួន ពិតជាបានព្រមព្រៀងក្នុងការលក់អចលនវត្ថុ ដែលមានទីតាំងស្ថិតនៅ ចំណុចភូមិព្រៃពាយ និងភូមិដុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ទៅឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីពិតមែន ប៉ុន្តែអចលនវត្ថុដែលជនជាប់ចោទបានព្រមព្រៀងក្នុងការលក់នេះ គឺជាដីព្រៃ ដែលជាប្រភេទដីសាធារណៈរបស់រដ្ឋ ដែលផ្អែកច្បាប់ភូមិបាល គឺជនជាប់ចោទពុំមានសិទ្ធិយកធ្វើជាកម្មសិទ្ធិ ឬ ធ្វើការចាត់ចែងនោះ ឡើយ ហើយចំពោះ ដីមួយភាគធំ ពុំមែនជាដីដែលជនជាប់ចោទបានអាស្រ័យផលទេ គឺជាដីដែលប្រជាពលរដ្ឋបានអាស្រ័យផលទៀត ផង ។ ហេតុនេះ ឃើញថាចាប់តាំងពីបានចុះកិច្ចសន្យាលក់ដីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ពីដំបូងមក គឺជនជាប់ចោទពុំមានលក្ខណៈសម្បត្តិត្រឹមត្រូវ តាមផ្លូវច្បាប់ក្នុងការលក់ដីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ ទោះបីជាជនជាប់ចោទ គ្មានលទ្ធភាពក្នុងការអនុវត្តសិទ្ធិជាអ្នកលក់ដោយស្របច្បាប់ លើអចលនវត្ថុដែលបានលក់នោះ ក៏ជនជាប់ចោទបានចុះការព្រមព្រៀង ក្នុងការលក់ដីទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីដដែល ។ ហេតុនេះ ឃើញថាជនជាប់ចោទបានដឹងរួចជាស្រេចទៅហើយថា អំពើរបស់ខ្លួន គឺជាអំពើខុសច្បាប់ ប៉ុន្តែជនជាប់ចោទនៅតែប្រព្រឹត្ត ដែលបង្ហាញថា ជនជាប់ចោទ គឺពិតជាបានប្រើឧបាយកលទុច្ចរិត និងគៃបំបាត់ ក្នុងការបោកប្រាស់យកប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណី ។

៧-ដោយផ្អែកតាមសំអាងហេតុខាងលើនេះ គឺពិតជាមានភស្តុតាងដាក់បន្ទុក និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ អាចឱ្យតុលាការកំណត់ និងប្រកាសថាពិតជាមានពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] នួន ពីបទ **រអាក** និងបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិព្រៃពាយ និងភូមិដុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត កាលពីអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាម មាត្រា៣៧៧ មាត្រា៣៧៨ មាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។ ដោយឡែកចំពោះការចោទប្រកាន់លើជនជាប់ចោទ ក្នុងអង្គហេតុនេះ ដោយគិតមកដល់បច្ចុប្បន្ន របស់តំណាងអយ្យការ និងចៅក្រមស៊ើបសួរនោះ គឺជាការចោទប្រកាន់ដែលពុំត្រឹមត្រូវទាល់តែសោះ ដោយសារបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្ត គឺត្រូវបានបញ្ចប់រួចទៅហើយនៅពេលដែលកម្លាំងមានសមត្ថកិច្ចឃាត់ខ្លួន ឬចាប់ខ្លួនជនជាប់ចោទបាន ។

៨-ជនជាប់ចោទឈ្មោះ [redacted] នួន បាននិយាយសំដីចុងក្រោយនាពេលសវនាការថា នៅពេលនេះខ្លួនសុំឱ្យតុលាការមេត្តារកយុត្តិធម៌ដល់ខ្លួន និងលើកលែងការចោទប្រកាន់ដល់ខ្លួនផង ព្រោះខ្លួនមានកូនតូចៗបួននាក់ត្រូវការអ្នកមើលថែ ។ ដោយហេតុនេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទ តាមការកំណត់ក្នុងមួយសមស្របតាមបទ បទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា៨ នៃក្រមព្រហ្មទណ្ឌ ។

ជនជាប់ចោទបានចុះហត្ថលេខាតាមច្បាប់ដើម
ថ្ងៃទី ...ខែ ...ឆ្នាំ ...ព.ស ...
ថ្ងៃទី ...ខែ ...ឆ្នាំ ...គ.ស ...

៩-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុល បានចូលមកប្តឹងទាមទារ នៅចំពោះមុខចៅក្រមស៊ើបសួរថា ខ្លួនប្តឹងទាមទារប្រាក់ដែលបាត់បង់ចំនួន ៨៦៧.៥០០ ដុល្លារអាមេរិក និងទាមទារសំណងជំងឺចិត្តចំនួន ១.៥០០.០០០ ដុល្លារអាមេរិក មកវិញ ព្រមទាំងសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ ។ ដោយហេតុជនជាប់ចោទ គឺ

ពិតជាមាន ពិរុទ្ធភាពដូចការចោទប្រកាន់ ហើយអំពើរបស់ជនជាប់ចោទ គឺពិតជាបានបង្កឱ្យមានការខូចខាតដល់ជនរងគ្រោះ មែន នោះគប្បីតុលាការបង្គាប់ឱ្យជនជាប់ចោទ សងការខូចខាតឱ្យជនរងគ្រោះវិញ ដោយយោងតាមមាត្រា១៣ មាត្រា១៤ និងមាត្រា២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សេចក្តីសម្រេច

ហេតុដូច្នេះ សាលាដំបូងខេត្តកំពត សម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] នួន ជានីតិជន (មានសាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០៩(ប្រាំបួន)ខែ ពីបទ **ធបោក** និងបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចភូមិព្រៃពាយ និងភូមិដុំផ្តៅ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត កាលពីអំឡុងខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០២១ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាម មាត្រា ៣៧៧ មាត្រា ៣៧៨ មាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] នួន សងសំណងថ្នៃការខាតបង់ ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុល ជាទឹកប្រាក់ចំនួន ៦១៧.៥០០ (ហុកសិបមួយម៉ឺនប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក និងជំងឺចិត្តជាទឹកប្រាក់ចំនួន ៥.000.000(ប្រាំលាន)រៀល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២ និងប្រកាសសាលក្រម នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ចាត់ទុកចំពោះមុខជនជាប់ចោទឈ្មោះ [redacted] នួន និងកំពាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ប៊ុល ។ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី

ហត្ថលេខា និងត្រា [redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា [redacted]

បានឃើញ

ចៅក្រម

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៣កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ពស២៥៦៦

កំពត, ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ[illegible]ខែ[illegible]..ឆ្នាំ..ឆ.ស..ព.ស២៥៦៦

..ត្រូវនឹងថ្ងៃទី..ខ..ខែ..ធ្នូ..ឆ្នាំ២០[illegible]

ក្រឡាបញ្ជី

[redacted]